# សេចក្តីសង្ខេបអំពីផែនការជនជាតិដើមភាគតិច

ខែមេសា ឆ្នាំ២០២៤

## គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ (NRRPCP)

សម្រាប់គម្រោងស្រះសហគមន៍ ភូមិសំរោង ឃុំប្រឡាយ ស្រុកថ្មបាំង ខេត្ត
កោះកុង (KKG-CP002)

## ក. សារបានគម្រោង

១. ក្រសួងអភិវឌ្ឍន៍ជនបទបានទទួលហិរញ្ញប្បទានពីធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) តាមរយៈរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (GoKC) ក្នុងគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ (NRRPCP) ដែលគម្រោងនេះត្រូវបានចាត់ជាអាទិភាពបន្ទាន់នៃការឆ្លើយតប លើការរីករាលដាលនៃជម្ងឺ COVID-19 និងជាផ្នែកមួយនៃការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធជនបទដែលបានរងផលប៉ះពាល់។

២. ក្រសួងអភិវឌ្ឍន៍ជនបទ ទទួលខុសត្រូវលើការសម្របសម្រួលគម្រោងទាំងមូលរួមមាន ការធ្វើផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ លទ្ធកម្ម ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃគម្រោង ។ គម្រោងមានខេត្តគោលដៅចំនួន ០៥ រួមមាន÷ខេត្តប៉ៃលិន (PLN) ខេត្តកំពង់ឆ្នាំង (KCH) ខេត្តកោះកុង (KKG) ខេត្តព្រៃវែង (PVG) និងខេត្តត្បូងឃ្មុំ (TKM) ដែលអនុវត្តគឺចាប់ពីខែកុម្ភៈ ឆ្នាំ២០២១ ដល់ខែធ្នូ ឆ្នាំ២០២៥។

៣. គម្រោងមានគោលបំណងសម្រេចឱ្យបាននូវនិរន្តរភាពសេដ្ឋកិច្ចជនបទ និងស្តារឡើងវិញនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទដែលងាយរងគ្រោះ និងប្រជាពលរដ្ឋដែលត្រឡប់ពីចំណាកស្រុក ដោយសារជំងឺកូវីដ១៩។ ក្នុងនោះដែរ សកម្មភាពចំបងរបស់គម្រោងក្នុងការស្តារឡើងវិញនូវជីវភាពប្រជាពលរដ្ឋគឺធ្វើឡើងតាមរយៈការស្ថាបនាផ្លូវជនបទចំនួន ២៣៥គីឡូម៉ែត្រ ព្រមទាំងស្តារឡើងវិញនូវស្រះសហគមន៍ចំនួន ៧៥ និងសង់ថ្មីចំនួន ៧៥ ក្នុងខេត្តគោលដៅនីមួយៗ។

៤. គម្រោងស្រះសហគមន៍ចំនួន ២៤ស្រះ ត្រូវបានជ្រើសរើសបន្ទាប់ពីពីប្រជុំពិគ្រោះយោបល់ជាច្រើនលើកច្រើនសារជាមួយប្រជាពលរដ្ឋអាស្រ័យផលក្នុងសហគមន៍និងអាជ្ញាធរ ព្រមទាំងចុះពិនិត្យទីតាំងជាក់ស្តែងដែលក្នុងនោះស្រះសហគមន៍ត្រូវស្តារឡើងវិញចំនួន ១២ និងស្រះដែលត្រូវសាងសង់ថ្មីចំនួន ១២ ក្នុងខេត្តកោះកុង។

៥. ក្រុមការងារទឹកស្អាត សំអាត និងអនាម័យ ជាមួយនឹងក្រុមហ៊ុនទីប្រឹក្សា (SP3) បានចុះត្រួតពិនិត្យវាយតម្លៃលើផ្នែកបរិស្ថាន និងសង្គម ដោយមានការសហការពី PIU អាជ្ញាធរមូលដ្ឋាន និងសហគមន៍ ព្រមទាំងក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ (WSUG)។ បញ្ជីត្រួតពិនិត្យការវាយតម្លៃផ្នែកបរិស្ថាន និងសង្គម (RESA) សម្រាប់អនុគម្រោងស្រះសហគមន៍នីមួយៗ បានសិក្សាវាយតម្លៃដោយអ្នកជំនាញផ្នែកបរិស្ថាននិងសង្គម ហើយលទ្ធផលនៃការសិក្សានេះទទួលបានការយល់ព្រមឯកភាពពីអាជ្ញាធរមូលដ្ឋាន និងអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត ។ ក្នុងចំណោមស្រះសហគមន៍ចំនួន ២៤ ក្នុងខេត្តកោះកុង គឺមានស្រះសហគមន៍តែមួយប៉ុណ្ណោះ ដែលមានវត្តមានជនជាតិដើមភាគតិច ជាសហគមន៍ជនជាតិដើមជង ដែលមានទីតាំងនៅភូមិសំរោង ឃុំប្រឡាយ ស្រុកថ្មបាំង។

## ខ. ផែនការជនជាតិដើមភាគតិច

៦. គម្រោងត្រូវរៀបចំផែនការជនជាតិដើមភាគតិច (IPP) សម្រាប់គម្រោងនីមួយៗដែលមានវត្តមានជនជាតិ

ដើមភាគតិច (IP) ទោះបីជាមិនមានផលប៉ះពាល់អវិជ្ជមានលើពួកគេក៏ដោយ។ លើសពីនេះទៅទៀត PIU និងអាជ្ញាធរស្រុកបានលើកឡើងនូវកង្វល់បន្ថែមមួយចំនួនទាក់ទងនឹងបញ្ហាប្រឈមក្នុងការជ្រើសរើសអនុគម្រោងនៅក្នុងភូមិដែលមានជនជាតិដើមភាគតិច ដែលអាចបណ្តាលឱ្យមានផលវិបាកមួយចំនួនរួមមាន (១) បន្ទុកលើមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត (PDRD) លើការជ្រើសរើសអនុគម្រោងដែលគ្មានជនជាតិដើមភាគតិចនៅក្នុងស្រុកថ្មបាំង (២)ជនជាតិដើមភាគតិចនៅក្នុងសហគមន៍ ពួកគេមានការយល់ច្រលំថាគម្រោងនេះមិនបានផ្តល់ផលប្រយោជន៍ជូនសហគមន៍ជនជាតិដើមភាគតិច និង (៣) សហគមន៍ជនជាតិដើមភាគតិច មានការព្រួយបារម្ភថាពួកគេមិនទទួលបានអត្ថប្រយោជន៍ស្មើគ្នាពីគម្រោងក្នុងនាមជាប្រជាពលរដ្ឋខ្មែរ ហើយនៅតែរស់នៅក្នុងស្ថានភាពក្រីក្រដែលបណ្តាលមកពីភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍របស់ពួកគេ។

៧. ផ្អែកលើការរចនាប្លង់បច្ចេកទេស ដីដែលបានផ្តល់សម្រាប់សាងសង់ស្រះសហគមន៍មានទំហំ ៧៥ ម៉ែត្រ គុណនឹង ៤០ ម៉ែត្រ។ លើសពីនេះ ការពិគ្រោះយោបល់ដែលបានធ្វើឡើងជាមួយជនជាតិដើមភាគតិច និងអាជ្ញាធរពាក់ព័ន្ធបានបង្ហាញថា អនុគម្រោងនឹងមិនមានផលប៉ះពាល់អវិជ្ជមានដល់ជនជាតិដើមភាគតិចដែលរស់នៅក្នុង និងជុំវិញតំបន់នៃគម្រោងនោះទេ។ ផ្ទុយទៅវិញ វានឹងផ្តល់អត្ថប្រយោជន៍មួយចំនួនដល់ពួកគេក៏ដូចជាប្រជាពលរដ្ឋខ្មែរ តាមរយៈការផ្តល់នូវភាពងាយស្រួលក្នុងការទទួលបានទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ការចិញ្ចឹមសត្វ និងការដាំបន្លែ ព្រោះថាតំបន់នេះពិតជាមានបញ្ហាប្រឈមខ្វះទឹកក្នុងរដូវប្រាំង។

៨. តាមរយៈការមើលឃើញពីស្ថានភាពជាក់ស្តែងបែបនេះ ទើបគម្រោងត្រូវបានចាត់ថ្នាក់ឡើងវិញពីផលប៉ះពាល់ជាវិជ្ជមានផ្នែកកិច្ចគាំពារសុវត្ថិភាពជនជាតិដើមភាគតិចប្រភេទ **ក** មកជាផលប៉ះពាល់ជាវិជ្ជមានផ្នែកកិច្ចគាំពារសុវត្ថិភាពជនជាតិដើមភាគតិចប្រភេទ **ខ** ដើម្បីឲ្យជនជាតិដើមភាគតិចបានទទួលផលប្រយោជន៍ពីគម្រោងផងដែរដោយអនុវត្តតាមគោលការណ៍ណែនាំរបស់ធនាគារ AIIB លើកិច្ចគាំពារសុវត្ថិភាពបរិស្ថាននិងសង្គមផ្នែកទី៣ ។

## គ. អំពីអនុគម្រោង

៩. អនុគម្រោងស្រះសហគមន៍ (KKG-CP002) ដែលនឹងសាងសង់ មានទីតាំងនៅភូមិសំរោង ឃុំប្រឡាយ ស្រុកថ្មបាំង ខេត្តកោះកុង។ ភូមិសំរោង ជាភូមិមួយក្នុងចំណោមភូមិទាំងបួនក្នុងឃុំប្រឡាយ ដែលមានប្រជាពលរដ្ឋចំនួន ២៣៤នាក់ ស្មើនឹង ៧៦គ្រួសារ ក្នុងនោះស្ត្រី ចំនួន១២៤នាក់។ ភូមិសំរោងមានតែ ១៦ គ្រួសារ តែប៉ុណ្ណោះដែលមានប័ណ្ណក្រីក្រ និង៥៥គ្រួសារទៀត ជាគ្រួសារជនជាតិដើមភាគតិច។

១០. អនុគម្រោងស្រះសហគមន៍នេះនឹងត្រូវសាងសង់លើដីដែលមានដើមឈើតូចៗ និងវាលស្មៅ ស្ថិតនៅខាងក្រោយសាលាឃុំប្រឡាយប្រហែល ២៥០ ម៉ែត្រ។

*រូបភាពទី 1: ផែនទីទីតាំងនៃអនុគម្រោងដែលបានស្នើឡើង*




១១. អនុគម្រោងស្រះសហគមន៍នេះ មានជនជាតិដើមភាគតិចតែមួយប្រភេទប៉ុណ្ណោះគឺ ជនជាតិជងដែលពួកគេបានសម្របខ្លួនក្នុងការរស់នៅយ៉ាងពេញលេញជាមួយប្រជាជនខ្មែរដទៃទៀតនៅក្នុងភូមិ។ របៀបនៃការស្លៀកពាក់ ការសន្ទនា ជីវភាព និងការរស់នៅរបស់ពួកគេគឺស្រដៀងទៅនឹងអ្នកភូមិខ្មែរស្ទើរតែទាំងស្រុង យើងស្ទើរតែមិនអាចសម្គាល់ថាពួកគេជាជនជាតិដើមភាគតិច ប្រសិនបើពួកគេមិននិយាយភាសារបស់ពួកគេ។

**គ.១ លក្ខណៈបទដ្ឋានបច្ចេកទេស**

១២. ស្រះសហគមន៍នេះនឹងត្រូវសាងសង់តាមស្តង់ដាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ ស្រះនេះមានទំហំ ៧៥ម៉ែត្រ គុណនឹង ៤០ម៉ែត្រ ដោយមានជើងទេរក្នុងកម្រិត ១:២ និងទំនប់ព័ទ្ធជុំវិញមាត់ស្រះមានទទឹងបាត ៤ម៉ែត្រ និងទទឹងផ្ទៃខាងលើមួយម៉ែត្រ។ ស្រះនេះជាស្រះដី ហើយមាត់ស្រះមានដាំស្មៅជុំវិញ។

១៣. ផ្ទៃដីសម្រាប់សាងសង់ស្រះនេះជាកម្មសិទ្ធិរួម របស់ឃុំ ហើយប្រធានក្រុមប្រឹក្សាឃុំ បានឯកភាពទទួលស្គាល់ជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ភូមិសម្រាប់ការប្រើប្រាស់ដីលើការសាងសង់ស្រះសហគមន៍នេះ។

*រូបភាពទី 2: ប្លង់វិស្វកម្មបច្ចេកទេសលម្អិតនៃស្រះសហគមន៍*




## ឃ. ការវាយតម្លៃផលប៉ះពាល់សង្គម (SIA)

១៤. ការវាយតម្លៃផលប៉ះពាល់សង្គម (SIA) សម្រាប់គម្រោងស្រះសហគមន៍នៅក្នុងភូមិសំរោងនេះ ត្រូវបានធ្វើឡើងដើម្បីស្វែងយល់ពីស្ថានភាពសេដ្ឋកិច្ចសង្គម និងផលប៉ះពាល់ដែលអាចកើតមានលើសហគមន៍ជនជាតិដើមភាគតិចផង។ ការវាយតម្លៃនេះរួមមានការពិនិត្យលើទិន្នន័យដែលមានស្រាប់ និងការប្រមូលទិន្នន័យចម្បងនៅមូលដ្ឋានផ្ទាល់ និងកិច្ចប្រជុំពិគ្រោះយោបល់សាធារណៈជាមួយសហគមន៍ជនជាតិដើមភាគតិច។

១៥. ការពិនិត្យលើទិន្នន័យដែលមានស្រាប់÷ គឺជាធាតុផ្សំដ៏សំខាន់នៃវិធីសាស្ត្រ SIA ដោយផ្តោតលើការវិភាគឯកសារដែលមានស្រាប់ ក្របខ័ណ្ឌច្បាប់ និងគោលការណ៍ណែនាំពាក់ព័ន្ធនានាហើយនេះក៏ពាក់ព័ន្ធនឹងការពិនិត្យមើលឯកសារគម្រោង គោលនយោបាយ ស្តង់ដារបរិស្ថាននិងសង្គម (ESS) របស់ AIIB ដើម្បីធានាបាននូវការអនុលោមតាមកិច្ចគាំពារសុវត្ថិភាពសង្គម។ លើសពីនេះ ទិន្នន័យភូមិសាស្ត្រទាក់ទងនឹងជនជាតិដើមភាគតិច ត្រូវបានពិនិត្យដើម្បីស្វែងយល់ពីបរិបទប្រជាសាស្ត្រ និងតម្រូវការជាក់លាក់របស់សហគមន៍ជនជាតិជង ក្នុងភូមិសំរោង។ ការពិនិត្យឡើងវិញនេះបានឲ្យដឹងនូវព័ត៌មានមូលដ្ឋានមួយចំនួន ដូចជា បរិបទរស់នៅ បរិស្ថានជុំវិញសហគមន៍ សាវតាសេដ្ឋកិច្ចសង្គមរបស់សហគមន៍ជន

ជាតិដើមភាគតិច និងសក្តានុពលនៃគម្រោង ដើម្បីឈានទៅកំណត់ការប្រមូលទិន្នន័យចម្បងនៅមូលដ្ឋានផ្ទាល់។

១៦. ការប្រមូលទិន្នន័យចម្បងនៅមូលដ្ឋានផ្ទាល់÷ ការប្រមូលទិន្នន័យនេះធ្វើឡើងចាប់ពីថ្ងៃទី ៤ ដល់ថ្ងៃទី ១១ ខែមីនា ឆ្នាំ២០២៤ ពីមូលដ្ឋានសហគមន៍ជនជាតិដើមភាគតិចជង។ ការងារនេះរួមមានការពិគ្រោះយោបល់ជាសាធារណៈ ការពិភាក្សាជាមួយក្រុមគោលដៅ (FGDs) និងបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs)។ FGDs និង KIIs ចំនួន ២ត្រូវបានធ្វើឡើងដោយមានការចូលរួមពីតំណាងសមាជិកសហគមន៍ ដើម្បីពិភាក្សាអំពីស្ថានភាពសេដ្ឋកិច្ចសង្គម ទិដ្ឋភាពវប្បធម៌ និងផលប៉ះពាល់នានាដែលអាចកើតមានពេលអនុវត្តគម្រោង។ គ្រួសារជនជាតិដើមភាគតិចសរុបចំនួន ៤១ គ្រួសារ ក្នុងចំណោម ៥៥គ្រួសារ នៅក្នុងភូមិសំរោងត្រូវបានសំភាសន៍ដើម្បីវាយតម្លៃពីកម្រិតជីវភាពរស់នៅ ប្រភពចំណូល និងការយល់ឃើញរបស់ពួកគេលើការសាងសង់ស្រះសហគមន៍នេះ។

## ង. លទ្ធផលនៃការវាយតម្លៃផលប៉ះពាល់សង្គម

១៧. ព័ត៌មានប្រជាសាស្ត្រ ស្ថានភាពសេដ្ឋកិច្ចសង្គម និងអត្ថប្រយោជន៍គម្រោង÷ លទ្ធផលបានបង្ហាញថាភូមិសំរោងមានប្រជាជនសរុបចំនួន ២៣៤នាក់ ស្មើនឹង៧៦គ្រួសារ និង៧២.៤% គឺជាជនជាតិដើមភាគតិចជង។ សមាជិកគ្រួសារជាមធ្យមគឺ ៣នាក់ក្នុងមួយគ្រួសារ ដោយភាគច្រើនប្រកបរបរកសិកម្មចិញ្ចឹមជីវិត អាជីវកម្មខ្នាតតូច និងការចិញ្ចឹមសត្វ។ ការធ្វើចំណាកស្រុកទៅកាន់ខេត្តក្រុងឬប្រទេសផ្សេងមានចំនួនតិចតួច ហើយប្រហែល ៧០% នៃចំនួនប្រជាជន មានកំរិតជីវភាពមធ្យមដោយផ្អែកលើទិន្នន័យជំរឿនថ្នាក់ជាតិរបស់ក្រសួងផែនការ ។ ទន្ទឹមនឹងនេះក្រុមការងារគម្រោងបានសង្កេតឃើញថាគម្រោងនេះមិនមានផលប៉ះពាល់ជាអវិជ្ជមានដោយសារការសាងសង់ស្រះសហគមន៍នេះទេ។ ផ្ទុយទៅវិញ គម្រោងនេះរំពឹងថានឹងផ្តល់អត្ថប្រយោជន៍ជាច្រើន ដូចជាការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានទឹកសម្រាប់កសិកម្ម ការចិញ្ចឹមសត្វ និងការប្រើប្រាស់ក្នុងគ្រួសារ គាំទ្រដល់ជីវភាពរស់នៅរបស់ពួកគេអោយកាន់តែមានភាពល្អប្រសើរ ។

១៨. ការអប់រំ ការប្រតិបត្តិវប្បធម៌ និងអត្ថប្រយោជន៍÷ ប្រជាពលរដ្ឋក្នុងសហគមន៍តិចតួចដែលទទួលបានការសិក្សាជ្រៅជ្រះ តែយ៉ាងហោចណាស់ក៏មានប្រជាពលរដ្ឋអាចសរសេរ និងអានអក្សរខ្មែរ ប្រមាណ ៨៥%។ ទំនៀមទំលាប់វប្បធម៌ ជំនឿសាសនា ការគោរពបូជាដូនតា និងពិធីប្រពៃណី នៅតែរឹងមាំ ឆ្លុះបញ្ចាំងពីការបន្តវប្បធម៌របស់សហគមន៍ ទោះបីជាមានការរួមបញ្ចូលជាមួយវប្បធម៌ខ្មែរក៏ដោយ។ គម្រោងស្រះសហគមន៍នេះនឹងផ្តល់អត្ថប្រយោជន៍បន្ថែម ដូចជាកាត់បន្ថយពេលវេលាទៅដងទឹកសម្រាប់ស្ត្រី និងអាចឱ្យពួកគេចូលរួមសកម្មភាពក្នុងសហគមន៍បានច្រើន និងមានប្រសិទ្ធភាពជាងមុន។ ស្រះសហគមន៍ក៏អាចក្លាយជាជាកន្លែងប្រមូលផ្តុំ ជំរុញការរួបរួមសង្គម និងគាំទ្រព្រឹត្តិការណ៍វប្បធម៌សង្គមរបស់ប្រជាពលរដ្ឋក្នុងភូមិ។

១៩. ហេដ្ឋារចនាសម្ព័ន្ធ លទ្ធភាពប្រើប្រាស់ទឹក និងវិធានការប្រុងប្រយ័ត្ន÷ គម្រោងស្រះសហគមន៍នេះអនុវត្តវិធានការប្រុងប្រយ័ត្នជាចំបងមួយចំនួនដើម្បីការពារផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានក្នុងដំណាក់កាលសាងសង់ រួមមាន ការបណ្តុះបណ្តាលការយល់ដឹងអំពីប្រពៃណីជនជាតិដើមភាគតិចសម្រាប់កម្មករ ដើម្បីការពារការបំពានដោយចៃដន្យលើប្រពៃណីជនជាតិដើមភាគតិច ជួលអ្នកបកប្រែភាសាជងដើម្បីដោះស្រាយឧបសគ្គភាសា និងការអនុវត្តស្តង់ដារនីតិវិធីរកឃើញដោយចៃដន្យនៃវត្ថុស័ក្តិសិទ្ធិ និង បុរាណវិទ្យាទាំងឡាយដែលបានរកឃើញក្នុងពេលជីកកកាយស្រះទឹក។ គម្រោងនឹងសហការយ៉ាងស្អិតរមួតជាមួយប្រជាពលរដ្ឋក្នុងហគមន៍ ជាពិសេសអ្នកម៉ៅការនឹងផ្តល់ជូនកាលវិភាគនៃការសាងសង់ ដើម្បីជៀសវាងការរំខានដល់ពិធីសាសនា។ វិធានការសកម្មភាពទាំងនេះមានគោលបំណងកាត់បន្ថយហានិភ័យ ផលប៉ះពាល់ជាអវិជ្ជមាននៃការសាងសង់ស្រះដែលអាចកើតឡើងដោយមិនបានព្រៀងទុកជាមុន ។

## ច. យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM)

២០. យន្តការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានរៀបចំឡើងដើម្បីដោះស្រាយកង្វល់របស់សហគមន៍ទាក់ទងនឹងគម្រោងស្រះសហគមន៍ ដើម្បីឲ្យមានតម្លាភាព ភាពងាយស្រួលក្នុងការប្រើប្រាស់ និងប្រកាន់ទំនៀមទំលាប់ជនជាតិដើមភាគតិច។

**យន្តការនេះមាន ៣ដំណាក់កាល÷**

**ដំណាក់កាលទី១÷** ប្រជាពលរដ្ឋឬសមាជិកសហគមន៍ដែលរងផលប៉ះពាល់អាចដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរទៅកាន់អ្នកម៉ៅការ ឬប្រធានភូមិ ដើម្បីទទួលបានការដោះស្រាយក្នុងរយៈពេល ៥ ថ្ងៃ។

**ដំណាក់កាលទី២÷** ប្រសិនបើមិនត្រូវបានដោះស្រាយទេ បណ្តឹងត្រូវបញ្ជូនបន្តទៅកាន់អង្គភាពអនុវត្តគម្រោង (PIU) ក្នុងរយៈពេល ៥ ថ្ងៃ ដើម្បីបន្តការដោះស្រាយជាផ្លូវការ។

**ដំណាក់កាលចុងក្រោយ÷** ប្រសិនបើបញ្ហានៅតែបន្តដោយមិនត្រូវបានដោះស្រាយក្នុងដំណាក់កាលទី២ទេ ដំណើរការដោះស្រាយនឹងត្រូវបានបន្តទៅកាន់អង្គភាពគ្រប់គ្រងគម្រោង (PMU) ដែលផ្តល់ការឆ្លើយតបចុងក្រោយក្នុងរយៈពេល ៥ ថ្ងៃ។

២១. GRM ត្រូវបានសង្កត់ធ្ងន់លើសមភាពយេនឌ័រ ដែលអនុញ្ញាតឱ្យមានការតវ៉ាដោយផ្ទាល់មាត់ ឬដោយមានជំនួយ ដោយធានាថាស្ត្រី និងក្រុមងាយរងគ្រោះអាចចូលរួមបាន។ យន្តការដោះស្រាយក៏ត្រូវរួមបញ្ចូលអ្នកបកប្រែ និងអ្នកតំណាងសហគមន៍ដើម្បីជួយសម្រួលដល់ការប្រាស្រ័យទាក់ទងគ្នា ដោយមានការសម្រេចចិត្តចែករំលែកដោយតម្លាភាព។ លើសពីនេះ យន្តការដោះស្រាយអ្នកដែលរងផលប៉ះពាល់ពីគម្រោង (PPM) ធានាឱ្យមានការប្រកាន់ខ្ជាប់នូវគោលនយោបាយគាំពារសុវត្ថិភាពបរិស្ថាន និង

សង្គម (ESP) របស់ AIIB ផងដែរ។

## ឆ. ការត្រួតពិនិត្យ ការរាយការណ៍ និងការវាយតម្លៃ

២២. ក្របខណ្ឌត្រួតពិនិត្យ រាយការណ៍ និងវាយតម្លៃ (M&E) សម្រាប់គម្រោងស្រះសហគមន៍ផ្តោតលើការធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃផែនការជនជាតិដើមភាគតិច (IPP)។ ក្រុមហ៊ុនទីប្រឹក្សា SP3 ដោយមានការសហការជាមួយអង្គភាពអនុវត្តគម្រោងនៅថ្នាក់ខេត្ត (PIUs) និងអង្គភាពគ្រប់គ្រងគម្រោង (PMU) នឹងត្រួតពិនិត្យទីតាំងជាប្រចាំពីកិច្ចគាំពារសុវត្ថិភាព និងការប្រឹក្សាជាមួយសហគមន៍។ សកម្មភាព M&E នឹងតាមដានសូចនាករសំខាន់ៗដូចជា ការប្រើប្រាស់ទឹក ការការពារវប្បធម៌ និងការចូលរួមពីសហគមន៍ ដើម្បីអោយអង្គភាពគ្រប់គ្រងគម្រោងរៀបចំរបាយការណ៍ត្រួតពិនិត្យបរិស្ថាន និងសង្គមប្រចាំឆមាស (SEMRs) ទៅកាន់ AIIB ។ របាយការណ៍នេះនឹងរួមបញ្ចូលទិន្នន័យជាក់លាក់អំពីយេនឌ័រ និងជនជាតិដើមភាគតិច ដែលធានានូវតម្លាភាព និងគណនេយ្យភាព។